**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៦៧ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការចាត់ថ្នាក់ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ការធ្វើអនុបយោគ និង ការប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ នៅតំបន់ដីផ្ទុង ឃុំត្រពាំងភ្លាំង ស្រុកឈូក និង ឃុំស្ទឹងកែវ ស្រុកកំពត ខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច

## សម្រេច

**មាត្រា ១ .-**

ត្រូវបានចាត់ថ្នាក់ជាព្រៃផ្តល់ផលសម្រាប់រក្សាទុកផលិតកម្មផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាព មានមុខងារការពារជាអាទិភាពនៃព្រៃឈើត្រូវស្តារឡើងវិញ នូវព្រៃបម្រុងទុកអចិន្ត្រៃយ៍ទំហំ ប្រាំបីរយសែសិបបួនហិកតា (៨៤៤ហ.ត) ស្ថិតនៅតំបន់ដីរំផុង ឃុំត្រពាំងភ្លាំង ស្រុកឈូក និង ឃុំស្ទឹងកែវ ស្រុកកំពត ខេត្តកំពត ដែលមាននិយាមកា: **A:** 412544, 1193749 **O:** 413279, 1193318 **X:** 410858, 1193347 **W:** 410846, 1197342 **V:**413495, 1197302 **S:** 413531, 1195828 **T:** 412559, 1195817 **U:** 412540, 1194822 ។

**មាត្រា ២ .-**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នូវព្រៃបំរុងទុកអចិន្ត្រៃយ៍ទំហំ ពីររយដប់ប្រាំបួនហិកតា (២១៩ហ.ត) ស្ថិតនៅតំបន់ដីរំផុង ឃុំត្រពាំងភ្លាំង ស្រុកឈូក និង ឃុំស្ទឹងកែវ ស្រុកកំពត ខេត្តកំពត ដែលមាននិយាមកា: **A:** 412544, 1193749 **B:** 412631, 1193735 **C:** 412795, 1193785 **D:** 412910, 1193796 **E:** 413035, 1193710 **F:** 413030, 1193669 **G:** 413064, 1193539 **H:** 413074, 1193518 **I:** 413091, 1193498 **J:** 413098, 1193475 **K:** 413115, 1193476 **L:** 413156, 1193451 **M:** 413226, 1193417 **N:** 413256, 1193376 **O:** 413279, 1193318 **P:** 413523, 1193326 **Q:** 413521, 1193663 **R:** 413513, 1194819 **S:** 413531, 1195828 **T:** 412559, 1195817 **U:** 412540, 1194822 ។

**មាត្រា ៣ .-**

ត្រូវបានផ្ទេរដីព្រៃ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀតទំហំ ពីររយដប់ប្រាំបួនហិកតា (២១៩ហ.ត) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។

**មាត្រា ៤ .-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ពីររយដប់ប្រាំបួនហិកតា (២១៩ហ.ត) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ៥ .-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ជូនអាជ្ញាធរកាន់កាប់ដីរដ្ឋខេត្តកំពត ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋទំហំ ពីររយដប់ប្រាំបួនហិកតា(២១៩ហ.ត)ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ សម្រាប់គោលដៅសម្បទានដីសង្គមកិច្ចតាមនីតិវិធីច្បាប់ជាធរមាន ។

**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ